**របាយការណ៍វឌ្ឍនភាព ស្តីពី**
**លទ្ធផល នៃការអនុវត្តន៍គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ច**
ពីខែមករា ដល់ ខែកញ្ញា ឆ្នាំ២០២០

**១-ក្រុមហ៊ុនឈ្មោះ** ៖ ហ្វ្រេនឌីស ធីមប៊ើរ អិលធីឌី

**២-ទីតាំងនិងទំហំផ្ទៃដី** ៖ ស្រុកភ្នំស្រួច និងស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ មានទំហំផ្ទៃដីសរុប ៧.៨៩៦,១១ ហិកតា

**៣-ប្រភេទដំណាំ** ៖ ដើមឈើម៉ៃសាក់

**៤-ផែនការមេ** ៖ ក្រសួង ☑ ឬ ខេត្ត ☐

- ផែនការមេថ្មី៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុម័តរួចរាល់ តាមលិខិតលេខ ២០២៤ កសក ចុះថ្ងៃទី២៧ ខែកុម្ភៈឆ្នាំ២០២០
- ផែនការមេចាស់៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុម័តរួចរាល់ តាមលិខិតលេខ ៣២៥៩/៣៣៦ កសក.រផ.ផក ចុះថ្ងៃទី០២ ខែ មិថុនា ឆ្នាំ ២០១០។

**៥-ការចុះបញ្ជីដីរដ្ឋ** ៖ បានទទួលប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុចំនួន ១៧ក្បាលដី

- អនុវត្តរួចរាល់ ☑ ស្នើផ្តល់ឯកសារ (១៧ ប្លង់ដី)
- កំពុងអនុវត្ត ☐ ដល់ណាស្នើបញ្ជាក់ និងផ្តល់ឯកសារ
- មិនបានអនុវត្ត ☐ មូលហេតុ

**៦-អនុបយោគ** ៖ វិញ្ញាបនប័ត្រសម្គាល់សិទ្ធិសម្បទានដីសេដ្ឋកិច្ចចំនួន ១៧ប័ណ្ណ (៧ ៨៩៦,១១ហិកតា)

- បានអនុវត្តរួចរាល់ ☑ ស្នើផ្តល់ឯកសារ (និងអនុក្រឹត្យលេខ១៧៥ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៧)
- កំពុងអនុវត្ត ☐ ដល់ណាស្នើបញ្ជាក់ និងផ្តល់ឯកសារ
- មិនបានអនុវត្ត ☐ មូលហេតុ

**៧-របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន៖**

- បានអនុវត្តរួចរាល់ ☑
  - របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ៖ អនុម័តរួចរាល់តាមលិខិតលេខ ១៥៦២ សជណ ប.ស្ក ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៩
  - របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានបឋម៖ អនុម័តរួចរាលតាមលិខិតលេខ ១៧២ ស.ជ.ណ ប.ស្ក ចុះថ្ងៃទី ១៧ ខែមិនា ឆ្នាំ២០១៤ របស់ក្រសួងបរិស្ថាន។
- កំពុងអនុវត្ត ☐ ដល់ណាស្នើបញ្ជាក់ និងផ្តល់ឯកសារ
- មិនបានអនុវត្ត ☐ មូលហេតុ

**៨-លិខិតអនុញ្ញាតឲ្យឈូសឆាយ៖**

- មាន ☑ គ្មាន ☐ អនុញ្ញាតដោយក្រសួង ឬខេត្ត
  - លិខិតលេខ.១៨៨ កសក ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៨ របស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ នៅអនុតំបន់ទី៧ ៨ ៩ និង១០ លើផ្ទៃទំហំសរុប ១២១២ហិកតា
  - លិខិតលេខ.៤០១២/២៥៦ កសក.នផ.ផក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅអនុតំបន់ទី៧, ៨ និង៩ លើផ្ទៃដីទំហំ ២០០០ហិកតា
  - លិខិតលេខ.៣២៥៩/៣៣៦ កសក.នផ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១០ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅអនុតំបន់ទី១ លើផ្ទៃដីទំហំ ៤០៧ហិកតា

**៩-ទីតាំង និងទំហំផ្ទៃដីដែលអនុញ្ញាតឲ្យឈូសឆាយដាំដុះ៖**

- អនុតំបន់ទី 0 ទំហំ 0 ហិកតា (គ្មានការឈូសឆាយថ្មីនោះទេក្នុងឆ្នាំ២០២០នេះ ដោយក្រុមហ៊ុនគ្រាន់តែធ្វើការសំអាតទីតាំងដីដែលបានឈូសឆាយពីមុនដើម្បីដាំដុះបន្តមានទំហំផ្ទៃដី ១១៣,៦១ហិកតា អនុតំបន់ទី ១៦ ក្នុងផែនការមេថ្មីចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០)

**១០-លទ្ធផលអនុវត្តបាន៖** (ប្រសិនបើមានអនុវត្តច្រើនអនុតំបន់ស្នើរាយការណ៍តាមអនុតំបន់នីមួយៗ)

**១០.១-ការឈូសឆាយ-ដាំដុះ**

- ឈូសឆាយបាន/ឈូសឆាយឡើងវិញ ១១៣,៦១ ហិកតា ក្នុងអនុតំបន់ទី ១៦
- ដាំដុះបាន/ដាំឡើងវិញ ១០១,៦០ ហិកតា ក្នុងនោះប្រភេទដំណាំដើមម៉ៃសាក់លើផ្ទៃដីទំហំ ៥៨,៦៣ហត ដើមប្រេងខ្យល់ផ្ទៃដីទំហំ ១២,៩០ហត និងប្រភេទផ្សេងៗផ្ទៃដីទំហំ ៣០,០៧ហត ក្នុងអនុតំបន់ទី ១៦
- ផ្ទៃដីនៅសល់មិនទាន់ដាំ ១២១,១៥ហិកតា ក្នុងអនុតំបន់ទី ៦ និង១០ (១១១,១០ហត សល់ពីឆ្នាំ២០១៨ និង១០,០៥ហត សល់ពីឆ្នាំ២០១៧)
- ផ្ទៃដីមិនអាចដាំដុះបាន 0 ហិកតា ក្នុងអនុតំបន់ទី 0 ស្នើបញ្ជាក់ពីមូលហេតុដីមិនអាចដាំបាន៖ ។ (*ស្នើបញ្ជាក់ចំនុចនិយាមកាទីតាំងដាំដុះ និងភ្ជាប់មកជាមួយផែនទីតំបន់ដាំដុះ*)

**១០.២-ការងារសាងសង់៖**

| **ប្រភេទសំណង់** | **ចំនួន** | **ប្រវែង/ទំហំ (គម ឬម²)** | **សម្គាល់** |
|---|---|---|---|
| សាងសង់ផ្លូវក្នុងតំបន់ដីសម្បទានចំនួន | ០២ | ២,៦ គម | |
| សាងសង់ផ្លូវក្រៅ តំបន់ដីសម្បទានចំនួន | 0 | 0 | |
| ប៉ុស្តិ៍យាមសន្តិសុខ | ០១ | ១០ម² | |
| ស្រះទឹក | ០២ | ៤៨០០ ម² | |
| សាងសង់លូថ្មី | ០៨ | ទីតាំង | |
| សាងសង់ទំនប់បង្ហៀរទឹក | ០១ | ២៣ម | |
| ជួសជុលផ្លូវក្នុងតំបន់ដីសម្បទានចំនួន | 0 | 0 | |

**១០.៣-ការងារប្រមូលសំណល់ឈើពីការឈូសឆាយក្នុងតំបន់សម្បទាន៖**

- ឈើមូលសរុប គ្មាន ម³ បង់ថ្លៃសួយសាររួច គ្មាន ម³
- ឈើមូលសរុបនៅសល់មិនទាន់បង់ គ្មាន ម³ បញ្ជាក់មូលហេតុ៖ គ្មានការឈូសឆាយនោះទេ
- កូនឈើសរុប គ្មាន ដើម បង់ថ្លៃសួយសាររួច គ្មាន ដើម
- កូនឈើសរុបមិនទាន់បង់ គ្មាន ដើម បញ្ជាក់មូលហេតុ៖ គ្មានការឈូសឆាយនោះទេ
- អុសសរុប គ្មាន ស្ទែរ បង់ថ្លៃសួយសាររួច គ្មាន ស្ទែរ
- អុសសរុបមិនទាន់បង់ គ្មាន ស្ទែរ បញ្ជាក់មូលហេតុ៖ គ្មានការឈូសឆាយនោះទេ

**១០.៤-ការប្រើប្រាស់កម្លាំងពលកម្ម៖**

- បុគ្គលិកខ្មែរសរុប ៥៥ នាក់ ប្រាក់បៀវត្សប្រចាំខែក្នុងម្នាក់ ៤៦៩,៤៥ដុល្លារអាមេរិក
- បុគ្គលិកបរទេសសរុប 0 នាក់ ប្រាក់បៀវត្សប្រចាំខែក្នុងម្នាក់ .
- កម្មករខ្មែរអចិន្ត្រៃយ៍សរុប ២៨ នាក់ ប្រាក់បៀវត្សប្រចាំខែក្នុងម្នាក់ ១៩០ដុល្លារអាមេរិក
- កម្មករបរទេសសរុប គ្មាន នាក់ ប្រាក់បៀវត្សប្រចាំខែក្នុងម្នាក់ គ្មាន
- កម្មករបណ្ដោះសរុប ៨១ នាក់ ប្រាក់បៀវត្សប្រចាំខែក្នុងម្នាក់ $៧,៣០/ថ្ងៃ

**១០.៥-ផ្ទៃដីប្រមូលផល៖**

- ទំហំផ្ទៃដីប្រមូលផលដំណាំចម្បង

១. ប្រភេទដំណាំ គ្មាន ចំនួន គ្មាន ហិកតា អនុតំបន់ទី គ្មាន

២.ប្រភេទដំណាំ............គ្មាន..........ចំនួន..........គ្មាន..........ហិកតា អនុតំបន់..........គ្មាន

- ទំហំផ្ទៃដីប្រមូលផលបន្ទាប់បន្សំ

១.ដំណាំ..........គ្មាន..........ចំនួន..........គ្មាន..........ហិកតា អនុតំបន់..........គ្មាន

២.ដំណាំ..........គ្មាន..........ចំនួន..........គ្មាន..........ហិកតា អនុតំបន់..........គ្មាន

**១០.៦-ការប្រើប្រាស់ផល-ផលិតផល៖**

- បរិមាណផល-ផលិតផលទទួលបានតាមប្រភេទដំណាំ៖

ដំណាំ.......គ្មាន ចំនួន.......គ្មាន តោន

ដំណាំ.......គ្មាន ចំនួន.......គ្មាន តោន

- បរិមាណនិងប្រភេទផល-ផលិតផលសរុបទទួលបាន៖

ដំណាំ.......គ្មាន ចំនួន.......គ្មាន តោន

ដំណាំ.......គ្មាន ចំនួន.......គ្មាន តោន

- បរិមាណនិងប្រភេទផល-ផលិតផលនាំចេញ៖

ដំណាំ.......គ្មាន ចំនួន.......គ្មាន តោន ទៅប្រទេស.......

ដំណា.......គ្មាន ចំនួន.......គ្មាន តោន ទៅប្រទេស.......

- បរិមាណនិងប្រភេទផល-ផលិតផលប្រើប្រាស់ក្នុងស្រុក៖

ដំណាំ.......គ្មាន ចំនួន.......គ្មាន តោន ទៅប្រទេស.......

ដំណាំ.......គ្មាន ចំនួន.......គ្មាន តោន ទៅប្រទេស.......

**១១.ការបង់ថ្លៃឈ្នួលសម្បទាន៖** មាន ☑ គ្មាន ☐ បើមាន៖

- ក្រុមហ៊ុនបានទទួលលិខិតលេខ ៨០៤៥/៨២៤ កសក.គបហ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០ ស្នើឱ្យក្រុមហ៊ុនបង់ថ្លៃសម្បទានដីសេដ្ឋកិច្ចចំនួន៤១ ៤៩៤,៤៤ដុល្លារអាមេរិក សម្រាប់ឆ្នាំ២០២០ចូលថវិការដ្ឋ ហើយក្រោយពេលបង់រួច ក្រុមហ៊ុននឹងធ្វើរបាយការណ៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានបង់រួចសម្រាប់ឆ្នាំ២០១៩ (២០១៩-២០២០) នូវទឹកប្រាក់សរុបចំនួន ៤១ ០៨៣,៦១ ដុល្លារអាមេរិក នៅធនាគារជាតិនៃកម្ពុជា និងធនាគារអេស៊ីលីដា ភីអិលស៊ី
- បានបង់រួចសម្រាប់ឆ្នាំ២០១៨ (២០១៨-២០១៩) នូវទឹកប្រាក់សរុបចំនួន ៤០ ៦៧៦,៨៦ដុល្លារអាមេរិក នៅធនាគារជាតិនៃកម្ពុជា និងធនាគារអេស៊ីលីដា ភីអិលស៊ី
- បានបង់រួចសម្រាប់ឆ្នាំ២០១៧ (២០១៧-២០១៨) នូវទឹកប្រាក់សរុបចំនួន ៤០ ២៧៤,១០ដុល្លារអាមេរិក នៅធនាគារជាតិនៃកម្ពុជា និងធនាគារអេស៊ីលីដា ភីអិលស៊ី
- បានបង់រួចសម្រាប់ឆ្នាំ២០១៥ និង២០១៦ (២០១៤-២០១៥ និង២០១៥-២០១៦) នូវទឹកប្រាក់សរុបចំនួន ៧៩ ៣៥៥,៩០ដុល្លារអាមេរិក នៅធនាគារជាតិនៃកម្ពុជា និងធនាគារកាណាឌីយ៉ា ក.អ កម្ពុជា

**១២.ទំនាស់ដីធ្លី និងការដោះស្រាយ៖** មាន ☑ គ្មាន ☐ បើមានស្នើអត្ថាធិប្បាយពី៖

➢ **ក-ទីតាំងទំនាស់ស្ថិតនៅអនុតំបន់ណា? ទំហំដីទំនាស់ប៉ុន្មានហិកតា? ចំណុចនិយាមកា?**

ចំនួនបញ្ហាដីធ្លីសរុបដែលបានកើតឡើងនៅក្នុងតំបន់សម្បទាន និងតំបន់អភិរក្សា (ស្តារឡើងវិញ) មានចំនួន ១៤៣ករណី ក្នុងនោះបញ្ហាដីធ្លីចំនួន ១០៨ករណី បណ្តាលមកពីការអនុវត្តដំណើរការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធក្នុងភូមិសាស្ត្រឃុំស្មើសាមគ្គី ស្រុកឱរ៉ាល់ និង២៩ករណីផ្សេងទៀតកើតឡើងនៅក្នុងភូមិសាស្ត្រឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច និងឃុំស្មើសាមគ្គី ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ដែលបណ្តាលមកពីការទន្ទ្រានយកដីក្នុងតំបន់ការពារប្រភពទឹក ទំនាស់ព្រំប្រទល់ ជាដើម។ ទំហំផ្ទៃដីដែលមានផលប៉ះពាល់ក្នុងភូមិព្រៃធំ ឃុំស្មើសាមគ្គី សរុប

មានផ្ទៃដីទំហំ១៥៩,៦៣ ហិកតា ស្ថិតនៅក្នុងតំបន់សម្បទាន និងតំបន់អភិរក្ស (តំបន់ស្ពាន និងតំបន់ទ្រនាប់អូរ)។ ដោយឡែក ផលប៉ះពាល់ដែលស្ថិតនៅក្នុងភូមិសាស្ត្រឃុំក្រាំងដីវ៉ាយ ភាគច្រើនជាទំនាស់ព្រំប្រទលរវាងតំបន់សម្បទានដីសេដ្ឋកិច្ច និងដីឯកជន *(ជូនភ្ជាប់ផែនទីតំបន់ទំនាស់)*។

➢ **ខ-ថ្ងៃ/ខែ/ឆ្នាំកើតទំនាស់ មូលហេតុទំនាស់ និងឯកសារពាក់ព័ន្ធ**

បញ្ហាដីធ្លីចំនួន ១០៨ ករណី ស្ថិតក្នុងភូមិសាស្ត្រឃុំរស្មីសាមគ្គី ត្រូវបានកើតដោយសារការអនុវត្តនីតិវិធីចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធនៅក្នុងអំឡុងខែសីហា និងខែកញ្ញា ឆ្នាំ២០១៩។ ប៉ុន្តែ បញ្ហា២៩ករណី ផ្សេងទៀត បានរកឃើញខណៈដែលក្រុមហ៊ុនធ្វើការពិនិត្យ ផ្ទៀងផ្ទាត់ព្រំប្រទល់សម្បទានដីសេដ្ឋកិច្ច និងល្បាតក្នុងតំបន់សម្បទានដីសេដ្ឋកិច្ច។ បញ្ហាដីធ្លីដែលស្ថិតនៅភាគខាងត្បូងភាគច្រើនកើតឡើងដោយសារការកំណត់សម្គាល់ព្រំប្រទល់មិនមានភាពច្បាស់លាស់រវាងសម្បទានដីសេដ្ឋកិច្ច និងដីឯកជន ជាពិសេសនៅត្រង់តំបន់ដែលមិនទាន់បានដាំដុះដើមឈើ។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងភូមិសាស្ត្រឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ទាំងតំបន់សម្បទានដីសេដ្ឋកិច្ច និងដីឯកជនសុទ្ធតែមានប្លង់រឹង(និយាមកា)ដូចគ្នា ដូចនេះវាងាយស្រួលក្នុងការដោះស្រាយដោយយោងលើបច្ចេកទេស និងនីតិវិធី។ ដោយឡែក បញ្ហាដីធ្លីកើតឡើងនៅភាគខាងជើងបានកើតឡើងក្នុងអំឡុងពេលអនុវត្តការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ដែលបញ្ហាដីធ្លីមានរហូតដល់ ១០៨ករណី ក្នុងនោះ០៦ករណី បានដោះស្រាយរួចរាល់តាំងឆ្នាំទៅ។ ប្រជាជនមានតែបង្កាន់ដៃទទួលស្គាល់សិទ្ធិ ដែលបញ្ជាក់ដោយអាជ្ញាធរឃុំ ប៉ុណ្ណោះ។

➢ **គ-វិធានការដោះស្រាយ និងលទ្ធផលដោះស្រាយ**

ចំពោះបញ្ហាដីធ្លីទាំងអស់ត្រូវបានធ្វើការកំណត់នូវឫសគល់នៃបញ្ហា និងកត់ត្រានៅក្នុងតារាងតាមដានបញ្ហាដីធ្លីរបស់ក្រុមហ៊ុន។ នៅក្នុងដំណើរការកំណត់បញ្ហានៃទំនាស់ដីធ្លីនីមួយៗ ក្រុមហ៊ុនធ្វើឡើងដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន (ភូមិ ឃុំ) រដ្ឋបាលព្រៃឈើ ប្រជាជនពាក់ព័ន្ធ ដើម្បីពិនិត្យផលប៉ះពាល់ជាក់ស្តែងនៅទីវាល ប្រមូលឯកសារនៃការកាន់កាប់ដីធ្លី និងឯកសារពាក់ព័ន្ធផ្សេងទៀត។ គិតត្រឹមឧសភាឆ្នាំ២០២០នេះ ក្រុមហ៊ុនមិនត្រឹមតែបានធ្វើការដោះស្រាយ សម្របសម្រួលបញ្ហាដីធ្លីក្រៅប្រព័ន្ធតុលាការប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានអនុវត្តច្បាប់ក្នុងកម្រិតមូលដ្ឋានដូចខាងក្រោម៖

- ដាក់ពាក្យប្តឹងទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី និងស្ថាប័នពាក់ព័ន្ធ ជំទាស់និងស្នើសុំការកែតម្រូវលើលទ្ធផលនៃវិនិច្ឆ័យក្បាលដីសម្រាប់ចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។
- បានជួបប្រជុំជាមួយប្រធានក្រុមការងារចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធថ្នាក់ស្រុក ដើម្បីស្វែងយល់ពីបញ្ហានិងកំណត់ទិសដៅដោះស្រាយបន្ត។
- ក្រុមហ៊ុនបានកំណត់មុខសញ្ញាអ្នកទាមទារ ទីតាំងទាមទារ (ទំនាស់) និងផែនទី ដើម្បីមានមូលដ្ឋានក្នុងរាយការណ៍ជូនមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីមានអន្តរាគមន៍។

ក្រុមហ៊ុនបានធ្វើរបាយការណ៍ស្តីពីបញ្ហាដីធ្លីខាងលើទៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ស្ពឺ ដើម្បីអន្តរាគមន៍ និងមានវិធានការ។

**១៣.ទំហំដីផ្ទៀលតាមបទបញ្ជា ០១៖**.................................គ្មាន....................................................... (ស្នើផ្តល់ឯកសារ)

**១៤.លទ្ធផលអនុវត្តខ្លឹមសារ ស.ជ.ណ តាមរបាយការណ៍របស់គណៈកម្មការអន្តរក្រសួង**(១)។

| លេខលិខិត សជណ | ខ្លឹមសារសម្រេចរបស់ ស.ជ.ណ | លទ្ធផលអនុវត្តបានតាមខ្លឹមសារ សជណ |
|---|---|---|
| លិខិតលេខ. ១០៨៤ សជណ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី | អនុញ្ញាតអោយក្រុមហ៊ុនហ្វ្រេនឌីសធីមបើរ អិលធីឌី បន្តនីតិវិធីដោះស្រាយផលប៉ះពាលជា មួយ ប្រជាជន និងចុះកិច្ចសន្យាឡើងវិញ | • បានចុះបញ្ជីដីធ្លីរួចរាល់<br>• ធ្វើអនុបយោគរួចរាល់ពីដីសាធារណៈ មកជាដីឯកជនរបស់រដ្ឋ<br>• ចុះកិច្ចសន្យាកែតម្រូវ ថ្ងៃទី០១ខែធ្នូ ឆ្នាំ២០១៧ |

| | | |
|---|---|---|
| | ដោយបន្ថយរយៈពេលពី៧០មក ត្រឹម ៥០ឆ្នាំវិញ | • បញ្ចប់ផែនការមេថ្មី និងអនុម័តរួចរាល់ |

[១] គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច

**១៥.ការអនុវត្តន៍បន្ទាប់ពីការណែនាំរបស់ក្រសួង ឬខេត្ត ៖** (ស្នើផ្តល់ឯកសារ)

| ល.រ | លេខលិខិត និងខ្លឹមសារ | លទ្ធផលអនុវត្តបានតាមការណែនាំរបស់ក្រសួង |
|---|---|---|
| ១ | លិខិតលេខ ៨០៤៥/៨២៤ កសក.គហ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីសំណើបង់ថ្លៃសម្បទានដីសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០២០ | • បានឯកភាព និងឆ្លើយតបទៅក្រសួងលើតាមលិខិតលេខ ៧២០១ កសក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០<br>• បានទទួលលិខិតស្នើសុំឱ្យបង់ថ្លៃសម្បទានដីសេដ្ឋកិច្ចឆ្នាំ២០២០ ចំនួន ៤១៤៩៤,៤៤ដុល្លារអាមេរិក |
| ២ | លិខិតលេខ. ៧៥១៤ កសក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧ករណីសំណើរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ឲ្យបានរួចរាល់តាមនីតិវិធី | ក្រសួងបរិស្ថានបានអនុម័តរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ពេញលេញ សម្រាប់គម្រោងវិនិយោគដាំដើមម៉ៃសាក់របស់ក្រុមហ៊ុនហ្វ្រេនឌីស ធីមប៊ើរ អិលធីឌីផ្ទៃដីទំហំ ៧.៨៩៦,១១ ហិកតា នៅខេត្តកំពង់ស្ពឺ តាម**លិខិតលេខ១៥៦២សជណ.បស្ត ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩** |

**១៦.សំណូមពររបស់ក្រុមហ៊ុន ៖**

តាមរយៈការបញ្ជាក់ខាងលើ ក្រុមហ៊ុនហ្វ្រេនឌីស ធីមប៊ើរ អិលធីឌី នៅមានសកម្មភាពមួយចំនួនដែលកំពុងជាប់គាំង និងរង់ចាំនីតិវិធីពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានកិច្ចអន្តរាគមន៍។ ដូចនេះ ក្រុមហ៊ុនយើងខ្ញុំសូមស្នើសុំដូចខាងក្រោម៖

- ស្នើសុំក្រសួងគាំទ្រក្រុមហ៊ុនយើងខ្ញុំ លើករណីស្នើសុំសិទ្ធិប្រើប្រាស់ដីព្រៃស្ពានីយផ្សព្វផ្សាយ និងស្តារព្រៃឈើឡើងវិញរស្មីសាមគ្គី ស្ថិតក្នុងភូមិសាស្ត្រឃុំរស្មីសាមគ្គី ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ដើម្បីដាំឈើ (ដៃគូឯកជន និងរដ្ឋ) លើផ្ទៃដីទំហំ ២ ២៥៩ហិកតា
- ស្នើសុំកិច្ចអន្តរាគមន៍ផ្លូវច្បាប់ដើម្បីដោះស្រាយលើករណីទន្ទ្រានយកដីសម្បទានរបស់ក្រុមហ៊ុន ដែលបានអនុវត្តការចុះបញ្ជីដីរដ្ឋ និងរៀបចំអនុបយោគរួចរាល់ ពីប្រជាជនដូចបានបញ្ជាក់ខាងលើដោយខុសច្បាប់៕

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅភ្នំពេញ ថ្ងៃទី........ខែ..............ឆ្នាំ២០២០

**ប្រធានប្រតិបត្តិ**